## Expressing pain



តើជនជាតិខ្មែរនឹងលាន់មាត់ដូចម្ដេចក្នុងស្ថានភាពខាងលើ?

មុតដៃនឹងកាំបិត៖ អ៊ុយ ឈឺ!
អ៊ឺះ មុតដៃបណ្ដោយ!
អ៊ឺះ ឈាមបាត់!

ឈឺពោះ៖ អ៊ុយ ឈឺពោះអា!
អ៊ុយ ម៉េចក៏ឈឺពោះម៉េះនៀក?

ឈឺក្បាល៖ អ៊ុយ ឈឺក្បាលដល់ហើយ!
អ៊ុយ ឈឺក្បាលចង់ប្រេះហើយនៀក!
អ៊ុយ ម៉េចក៏ឈឺក្បាលម៉េះនៀក?

| | |
|---|---|
| មុតដៃនឹង ... | to cut one's finger with ... |
| អ៊ុយ | exclamation for complaining such as when in pain, feeling lazy or bored |
| អ៊ឺះ | exclamation for a sudden happening |
| ... បណ្ដោយ / ... បាត់ | at the end of a sentence to express something unfortunate or disappointing |
| អា | very much (spoken form of ណាស់) |
| ម៉េះនៀក | spoken form of ម្ល៉េះនេះ<br>often used as ម៉េចក៏....ម៉េះនៀក = "Why... so...?" |
| ឈឺពោះ = ចុកពោះ | both can be used almost equally, but some people say that ឈឺ and ចុក are different feelings of abdominal pain |
| ដល់ហើយ | very much, extremely (to a degree that it is almost unbearable)[1] |
| ចង់ប្រេះ | almost breaks |

[1] E.g., ឃ្លានដល់ហើយ = I am very hungry; អាវអញ្ចឹងសោះថ្លៃដល់ហើយ = Such a shirt is so expensive!

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ជនជាតិខ្មែរមួយចំនួនជឿថា នៅពេលមុតដៃ ត្រូវយកសំបុកពីងពាងមកបិទនៅនឹងមុខរបួស ទើបអាចឃាត់ឈាមបានលឿន។ ប៉ុន្តែ បើតាមវិជ្ជាពេទ្យ សំបុកពីងពាងកខ្វក់ណាស់ អាចធ្វើឲ្យឆ្លងមេរោគចូលទៅក្នុងមុខរបួស។ អញ្ចឹងហើយ មិនគួរយកសំបុកពីងពាងមកបិទនៅនឹងមុខរបួសមុតដែលកំពុងចេញឈាមនោះទេ។ គឺត្រូវលាងនឹងទឹកឲ្យស្អាតសិន រួចហើយប្រើអាល់កុលដើម្បីសម្លាប់មេរោគ។

| | |
|---|---|
| សំបុកពីងពាង | spider web |
| របួស | wound |
| ឃាត់ | to stop |
| វិជ្ជាពេទ្យ | medicine, medical science |
| មេរោគ | microbe |
| ចេញឈាម | to bleed |
| លាងរបួស | to clean the wound |
| អាល់កុល | alcohol |
| សម្លាប់ | to kill |

## Additional dialogue

លក្ខិណា៖ កើតអីហ្នឹងរតនា?

រតនា៖ ខ្ញុំឈឺពោះតាំងពីព្រឹក អត់បាត់សោះ។ អត់ដឹងមកពីអី។

លក្ខិណា៖ ញ៉ាំអីខុសដឹង?

រតនា៖ អត់ដឹងដែរ។ តែប្រហែលមកពីខ្ញុំញ៉ាំម្ហូបសល់ពីម្សិលមិញហើយមើលទៅ។

លក្ខិណា៖ មានរាករអត់?

រតនា៖ ដូចជាអត់ផង។

លក្ខិណា៖ អញ្ចឹងមិនមែនមកពីញ៉ាំអីខុសទេមើលទៅ។ ប្រហែលរតនាឯងឈឺក្រពះហើយ។

| | |
|---|---|
| ម្ហូបសល់ | leftovers |
| មើលទៅ | looks like, probably, maybe |
| រាក | diarrhea |
| ដូចជាអត់ផង។ | I don’t think so. |
| ឈឺក្រពះ | stomach illness |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.